ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

# លិខិតបទដ្ឋានពាក់ព័ន្ធនឹង
# តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នៃក្រសួងមហាផ្ទៃ
# និង
# អង្គភាពក្រោមឱវាទ

ចាប់ពីថ្ងៃទ ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨

348
REG

sh: Law

ប្រមូលចងក្រងដោយ លោក ឌុច សុន

NCDD Library
000846

ភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៨

# អារម្ភកថា

ជារៀងរាល់ឆ្នាំខ្ញុំសង្កេតឃើញថា: មាននិស្សិតជាច្រើន មកពីមហាវិទ្យាល័យនានា ជាពិសេសសិស្សមកពីសាលាភូមិន្ទរដ្ឋបាល ក្រោយបញ្ចប់ការសិក្សាផ្នែកទ្រឹស្តី តែងតែមកបំពេញកម្មសិក្សា នៅក្រសួងមហាផ្ទៃ ដើម្បីសរសេរសារណា លើមុខវិជ្ជាផ្សេងៗស្ថិតក្នុងសមត្ថកិច្ច របស់ក្រសួងមហាផ្ទៃ ជាហូរហែរពុំដែលដាច់មួយឆ្នាំណាឡើយ ។

នៅពេលចុះបំពេញការងារជាក់ស្តែង មានកម្មសិក្សាការីខ្លះបានត្អូញត្អែរថា ពុំមានឯកសារគ្រប់គ្រាន់ពាក់ព័ន្ធ នឹងតួនាទីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធ របស់អង្គភាពជាច្រើនក្រោមឱវាទ របស់ក្រសួងមហាផ្ទៃ ដើម្បីសរសេរនិក្ខេបបទរបស់ខ្លួន ។ ពាក់ព័ន្ធនឹងកង្វះខាតឯកសារពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរបស់អង្គភាពនានា ចំណុះក្រសួងមហាផ្ទៃនេះ សូម្បីមន្ត្រីរាជការមួយចំនួន ក៏ពុំមានឯកសារទាំងនោះគ្រប់គ្រាន់ផងដែរ ។

ហេតុនេះដើម្បីបង្កលក្ខណៈងាយស្រួល ដល់ប្អូនៗជានិស្សិត ក៏ដូចជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ខ្ញុំបានប្រមូលចងក្រងនូវឯកសារ ដែលមានខ្លឹមសារពាក់ព័ន្ធ និងតួនាទី ភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធ របស់ក្រសួងមហាផ្ទៃ និង អង្គភាពក្រោមឱវាទ ដែលមានតាំងពីឆ្នាំ១៩៩៣ ដល់ ខែ ធ្នូ ឆ្នាំ ២០០៨ ។

ទោះបីជាមានការប្រមូលចងក្រងជាសៀវភៅ ក៏ពិតមែន ប៉ុន្តែខ្ញុំយល់ថា នៅមានឯកសារខ្លះពុំទាន់គ្រប់គ្រាន់នៅឡើយ ពិសេសឯកសារពាក់ព័ន្ធនឹងនាយកដ្ឋាន និងអង្គភាពនានា ចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ ។ ប្រការនេះសូម ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី មេត្តាអធ្យាស្រ័យនិងជួយផ្តល់ជាព័ត៌មានផង ដើម្បីបំពេញបន្ថែម ។

សូមឱ្យអ្នករាជការ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានការលូតលាស់ដោយបញ្ញា ជាប្រទីបសំរាប់បំរើការងារ ក្នុងតំណែងរបស់ខ្លួន ឱ្យបានសក្តិសមជាប្រទេសមួយ កំពុងឈានលើវិថីនីតិរដ្ឋពិតៗ ។

ភ្នំពេញ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨

ឌុច សុន

# មាតិកានុក្រម

| លេខរៀង | លំដាប់មាតិកា | ទំព័រ |
| --- | --- | --- |
| ១- | ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ។.............................. | ០១ |
| ២- | អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន។.............................. | ០៣ |
| ៣- | អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ។.............................. | ១២ |
| ៤- | អនុក្រឹត្យលេខ ០៨ អនប្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមអ្នកច្បាប់ និង នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និង អាស៊ាន ចំណុះក្រសួងមហាផ្ទៃ។.............................. | ២០ |
| ៥- | អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម និង នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ។.............................. | ២៤ |
| ៦- | អនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ។.............................. | ២៨ |
| ៧- | ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៨២ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៦ ថ្ងៃកំណើតនគរបាលជាតិ កម្ពុជា (១៦-៥-១៩៤៥)។.............................. | ២៩ |
| ៨- | អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងមហាផ្ទៃ មកជាអគ្គលេខាធិការដ្ឋានក្រសួងហាផ្ទៃ។.............................. | ៣០ |
| ៩- | អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០២ ស្តីពីការបង្កើតសាលាភូមិន្ទនគរបាល។.............................. | ៣៤ |

១០- អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលជាតិកម្ពុជា ។........................ ៣៦
១១- អនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ មកជា អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ.......................................................................... ៤០
១២- អនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ ។.......................................................................... ៤២
១៣- អនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការបង្កើតអគ្គនាយក ដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ ។.......................................................... ៤៦
១៤- អនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋាន សវនកម្មផ្ទៃក្នុង ក្រសួងមហាផ្ទៃ ។................................................... ៤៩
១៥- ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការកែ សម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើតអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន ។............................ ៥២
១៦- អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។............................................................................ ៥៧
១៧- សេចក្តីសំរេចលេខ៤៧ សសរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។.......................................................................... ៧០
១៨- សេចក្តីសំរេចលេខ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យច្រកចេញ ចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ស្រុក ខណ្ឌ ។.......................................................................... ៧៧
១៩- អនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការបង្កើតនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន ចំណុះក្រសួងមហាផ្ទៃ ។.......................................... ៨១

២០- អនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការប្តូរឈ្មោះ នាយកដ្ឋាននគរបាលសេដ្ឋកិច្ច មកជា នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ ។........................................................ ៨៣

២១- ប្រកាសលេខ០៩៥ ប្រក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធរបស់ ទីស្តីការក្រសួងមហាផ្ទៃ ។........................................................ ៨៥

២២- ប្រកាសលេខ ០៣១ ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច សិទ្ធិ និង រចនាសម្ព័ន្ធ របស់រដ្ឋបាលខេត្ត ក្រុង ។........................................................ ១២២

២៣- ប្រកាសលេខ៩៤០ ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាព រដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។........................................................ ១៤៣

២៤- ប្រកាសលេខ ៣៤៨ ប្រក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ ស្តីពីតួនាទី ភារកិច្ច របៀបរបប ការងារ និងរចនាសម្ព័ន្ធ នៃសាលាស្រុក ខណ្ឌ ។........................................................ ១៥១

២៥- ប្រកាសលេខ ៧៩១ ប្រក ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធ គ្រប់គ្រងរដ្ឋបាល ស្រុកសៀមរាប ខេត្តសៀមរាប និងស្រុកបាត់ដំបង ខេត្តបាត់ដំបង ។........................................................ ១៥៨

២៦- ប្រកាសលេខ ០៨១ ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធ របស់ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ។........................................................ ១៨៤

២៧- ប្រកាសលេខ ៤១៦ ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់ប៉ុស្តិ៍នគររដ្ឋបាល ។........................................................ ១៩២

២៨- ប្រកាសលេខ ១៩៥០ ប្រក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ។........................................................ ១៩៥

២៩- ប្រកាសលេខ ២០៥៨ ប្រក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០២ ស្តីពីការបង្កើត លេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាល ។........................................................ ២០៤

៣០- ប្រកាសលេខ ២៤៧៨ ប្រក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការបង្កើត ការិយាល័យ រដ្ឋបាល និង សរុប ចំណុះនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃអគ្គនាយកដ្ឋាន រដ្ឋបាលក្រសួងមហាផ្ទៃ ។........................................................ ២០៨

៣១- ប្រកាសលេខ ២៥១៧ ប្រក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការបង្កើតបន្ថែម ការិយាល័យចំណុះនាយកដ្ឋានកិច្ចការនយោបាយ ។........................................ ២០៩

៣២- ប្រកាសលេខ ១៤១ ប្រក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការធ្វើអធិការកិច្ចនៅ អង្គភាព ចំណុះក្រសួង និង ខេត្ត ក្រុង ។........................................ ២១១

៣៣- ប្រកាសលេខ ១០៥២ ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតបន្ថែម ការិយាចំណុះនាយកដ្ឋាន ក្រោមឱវាទ ទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។................ ២១៤

៣៤- ប្រកាសលេខ ១០២២ ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត ការិយាល័យ ថវិកា ខេត្ត ក្រុង ។........................................ ២១៦

៣៥- សេចក្តីសំរេចលេខ ៣៧៥ សសរ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធ របស់នាយកដ្ឋានផែនការសេដ្ឋកិច្ច ហិរញ្ញវត្ថុផ្នែករដ្ឋបាល ។ ២១៨

៣៦- ប្រកាស ១៩៥ ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីការកែប្រែភារកិច្ចរបស់ នាយកដ្ឋានភស្តុភារ និង សំភារៈបច្ចេកទេស ។........................................ ២២៣

៣៧- ប្រកាសលេខ ៤២០ ប្រក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ ស្តីពីការ បំពេញបន្ថែមភារកិច្ច និងរចនាសម្ព័ន្ធ របស់នាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។........................................ ២២៥

៣៨- ប្រកាសលេខ ២៩០៩ ប្រក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការប្តូរ ឈ្មោះការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន ចំណុះនាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ។........................................ ២២៧

៣៩- ប្រកាសលេខ ០២៤ ប្រក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៦ ស្តីពីការកែសំរួល ការិយាល័យទំនាក់ទនងសាធារណៈ មកជា ការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ចំណុះសាលាខេត្ត ក្រុង ។........................................ ២២៩

៤០- ប្រកាសលេខ ២១៦២ ប្រក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៦ ស្តីពីភារកិច្ចនិង រចនាសម្ព័ន្ធរបស់ លេខាធិការដ្ឋាន នាយកដ្ឋាននានា ចំណុះអគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ។........................................ ២៣២

# ព្រះរាជក្រម

នស/រកម/០១៩៦/០៨

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

---

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ដែលរដ្ឋសភា បានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ការបង្កើតក្រសួងមហាផ្ទៃ

**មាត្រា ១.–**

ត្រូវបានបង្កើតក្រសួងមហាផ្ទៃ ចំណុះរាជរដ្ឋាភិបាល។

**មាត្រា ២.–**

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចដឹកនាំ គ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់លើវិស័យរដ្ឋបាល ដឹកនាំគ្រប់គ្រងនគរបាលជាតិ ការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និង ការពារសុវត្ថិភាព ជូនប្រជាពលរដ្ឋ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.–**

ក្រសួងមហាផ្ទៃ ត្រូវដឹកនាំដោយសហរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី ដែលអាចអមដោយរដ្ឋលេខាធិការ និង/ឬ អនុរដ្ឋលេខាធិការតាមការចាំបាច់។

**មាត្រា ៤.–**

ការរៀបចំរចនាសម្ព័ន្ធ និង ការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៥.–**

បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១**
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
**ហ៊ុន សែន**

លេខ : ២២ ច.ល.
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់

### ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

****

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង ទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស.រកត. ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- តាមតម្រូវការ នៃការរៀបចំគ្រប់គ្រង និង ការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី

### សំរេច

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

មាត្រា ១ : អង្គភាពរដ្ឋបាលរបស់រដ្ឋ ត្រូវប្រមូលផ្តុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន ។ ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាននីមួយៗ ត្រូវដាក់ក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីមួយរូប ឬរដ្ឋលេខាធិការមួយរូប ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គ-

ភាពនានាចំណុះក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យ ។ ពុំអាចដាក់អង្គភាពថ្នាក់កណ្តាលណាមួយអោយស្ថិតនៅក្រោមឋានានុក្រមនៃក្រសួង ឬ រដ្ឋលេខាធិការដ្ឋានពីរ ឬ ច្រើនផ្សេងពីគ្នាបានឡើយ ។ ផ្ទុយទៅវិញ ក្រៅពីអង្គភាពដែលចំណុះទីស្តីការគណៈរដ្ឋមន្ត្រី គ្មានអង្គភាពរដ្ឋបាលណាមួយ ដែលមិនស្ថិតនៅក្រោមឋានានុក្រមនៃក្រសួង ឬ រដ្ឋលេខាធិការដ្ឋានណាមួយឡើយ លើកលែងតែអង្គភាព ឬ អាជ្ញាធរដែលមានស្វ័យភាព ។

មាត្រា ២ : អនុក្រឹត្យនេះមិនគ្របដណ្តប់ទៅលើការរៀបចំ និង ការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិឡើយ ។

## ជំពូកទី ២

## ការរៀបចំរចនាសម្ព័ន្ធ

មាត្រា.៣ : ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាននីមួយៗ រួមមាន ÷

–អង្គភាពកណ្តាលមួយ ឬច្រើនចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន

–អង្គភាពមូលដ្ឋាន (ខាងក្រៅ) ចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន

–គ្រឹះស្ថានសាធារណៈដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន

–ខុទ្ទកាល័យរបស់រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ដែលជាប្រធានស្ថាប័ន

មាត្រា ៤ : អង្គភាពកណ្តាលចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋាននីមួយៗ អាចមាន ÷

–អគ្គលេខាធិការដ្ឋានមួយ ក្នុងករណីពិសេស

–អគ្គនាយកដ្ឋានមួយ ឬច្រើន ដែលបែងចែកជានាយកដ្ឋាន

–អគ្គាធិការដ្ឋានមួយ ឬ អធិការដ្ឋានមួយ

–អគ្គនាយកដ្ឋាន ឬ នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅមួយ

–នាយកដ្ឋានជំនាញមួយចំនួន

មាត្រា ៥ : អង្គភាពមូលដ្ឋាន (ខាងក្រៅ) ចំណុះក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន រួមអាចមាន ÷

**ក–ថ្នាក់ខេត្ត - ក្រុង**

–មន្ទីរជំនាញដឹកនាំដោយប្រធានមន្ទីរ

–មន្ទីរជំនាញនីមួយៗ ចែកចេញជាការិយាល័យ ។

ក្រៅពីការិយាល័យមន្ទីរជំនាញនីមួយៗ អាចមានអង្គភាពចំណុះមួយចំនួនទៀត

**ខ–ថ្នាក់ស្រុក - ខណ្ឌ**

–ការិយាល័យមួយដែលចែកចេញជាផ្នែកផ្សេងៗ

ការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពមូលដ្ឋាន (ខាងក្រៅ) ទាំងនេះ នឹងត្រូវកំណត់ដោយអនុក្រឹត្យមួយផ្សេងទៀត ។

## ជំពូកទី ៣
## អំពីអគ្គនាយកដ្ឋាន

មាត្រា ៦ : ប្រព័ន្ធរដ្ឋបាលនៃក្រសួង ឬ រដ្ឋលេខាធិកាដ្ឋានទីមួយៗ ត្រូវរៀបចំអោយមានជាអគ្គនាយកដ្ឋាន ដែលបែងចែកជានាយកដ្ឋាន ។ នាយកដ្ឋានទីមួយៗ បែងចែកជាការិយាល័យ ។

ប្រព័ន្ធរដ្ឋបាលនៃក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ដូចបានរៀបរាប់រួចមកហើយនេះ ត្រូវរៀបចំតាមអង្គការលេខតំរូ ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

ការបង្កើតអគ្គនាយកដ្ឋាន និង នាយកដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យដែលនឹងបញ្ជាក់អំពីភារកិច្ច និងការរៀបចំរបស់អគ្គនាយកដ្ឋាន និង នាយកដ្ឋាន ។ ចំណែកការបង្កើតការិយាល័យក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសាមី ដែលនឹងបញ្ជាក់នូវភារកិច្ច នៃការិយាល័យនោះ ។

មាត្រា ៧ : អគ្គនាយកដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកមួយរូប ។ ក្នុងករណីចាំបាច់អាចមានអគ្គនាយករងជាជំនួយការ ។

នាយកដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធាននាយកដ្ឋានមួយរូប ។ ក្នុងករណីពិសេសប្រធាននាយកដ្ឋានមួយអាចមានឋានៈ និងបុព្វសិទ្ធិជាអគ្គនាយក ។ ប្រធាននាយកដ្ឋាន មានអនុប្រធាននាយកដ្ឋានមួយរូប ឬច្រើនរូបជាជំនួយការ ។ ការិយាល័យស្ថិតក្រោមការគ្រប់គ្រងរបស់នាយការិយាល័យមួយរូប ដែលមាននាយរងការិយាល័យជាជំនួយការ ។

អគ្គនាយក ប្រធាននាយកដ្ឋាន និង នាយការិយាល័យ ត្រូវទទួលខុសត្រូវចំពោះដំណើរការអង្គភាពរបស់ខ្លួន និង ការអនុវត្តន៍ភារកិច្ចដែលថ្នាក់លើប្រគល់អោយ តាមផែនកិច្ចអនុវត្តបទបញ្ជា និងការណែនាំរបស់ថ្នាក់លើក្នុងក្របខ័ណ្ឌច្បាប់ ។

មាត្រា ៨ : អគ្គនាយកត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ដោយយោងតាមសំណើរបស់ប្រធានស្ថាប័នសាមី ។

អគ្គនាយករងមានឋានៈសមមូលនិងប្រធាននាយកដ្ឋាន នឹងត្រូវតែងតាំងដោយអនុក្រឹត្យ ។ចាប់តាំងពីថ្នាក់អនុប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល រហូតដល់នាយការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់ប្រធានស្ថាប័ន ។ មន្ត្រីខាងលើនេះត្រូវតែងតាំងក្នុងចំណោមមន្ត្រីរាជការ ដែលមានក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ហើយត្រូវមានលក្ខណសម្បត្តិគតិវិជ្ជា សមត្ថភាពជំនាញ អតីតភាព ព្រមទាំងឋានន្តរសក្តិស្របតាមលក្ខន្តិកៈ ដោយឡែកនៃអង្គមន្ត្រីនីមួយៗ ។

មាត្រា ៩ : អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ត្រូវទទួលបន្ទុកការងាររដ្ឋបាល - បូកសរុប ភយការណ៍ ឯកសារ - បុគ្គលិក - ផែនការ - ហិរញ្ញវត្ថុ និងសម្ភារៈបរិក្ខារ

## ជំពូកទី ៤

## អំពីអគ្គាធិការដ្ឋាន ឬ អធិការដ្ឋាន

មាត្រា១០ : អគ្គាធិការដ្ឋាន ឬ អធិការដ្ឋាន មានភារកិច្ចត្រួតពិនិត្យ ដើម្បីអោយអង្គភាពរដ្ឋបាលកណ្តាល អង្គភាពមូលដ្ឋាន (ខាងក្រៅ) ចំណុះក្រសួង ឬរដ្ឋលេខាធិការដ្ឋាន មានដំណើរការល្អ ។ ក្នុងករណីនេះអគ្គាធិការដ្ឋាន ឬអធិការដ្ឋាន មានភារកិច្ចត្រួតពិនិត្យ ដំណើរការរបស់អង្គភាព និងនាយកដ្ឋានទាំងនោះអោយស្របតាមគោលច្បាប់ ស្របតាមទិសដៅ និងបទបញ្ជារបស់ប្រធានស្ថាប័ន ។ អគ្គាធិការដ្ឋាន ឬអធិការដ្ឋាន រាយការណ៍អំពីបេសកកម្មរបស់ខ្លួន ជូនប្រធានស្ថាប័ន ប៉ុន្តែពុំមានសិទ្ធិសំរេចជំនួសទេ ។

មាត្រា១១ : អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប អាចមានអគ្គាធិការរងជាជំនួយការ យោលទៅតាមតម្រូវការ ។ អធិការដ្ឋានដឹកនាំដោយអធិការមួយរូប អាចមានអធិការរង ១ ឬ ២ រូប ជាជំនួយការ ។

មាត្រា១២ : អគ្គាធិការមានឋានៈសមមូល និងអគ្គនាយក ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ដោយយោងសំណើប្រធានស្ថាប័នសាមី ក្នុងចំណោមអធិការរបស់ក្រសួងដែលមានគុណសម្បត្តិ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងកិច្ចការនេះ ។ រីឯអធិការមានឋានៈសមមូល និង ប្រធាននាយកដ្ឋានត្រូវតែងតាំង ដោយអនុក្រឹត្យតាមសំណើរបស់ប្រធានស្ថាប័នសាមីក្នុងចំណោមមន្ត្រីរាជការនៃក្រសួង ដែលធ្លាប់បំរើការយ៉ាងតិច ៥ ឆ្នាំ ជាមន្ត្រីទទួលខុសត្រូវខ្ពស់ ឬធ្លាប់មានតួនាទីសំខាន់ ។

អគ្គាធិការរង និងអធិការមានឋានៈសមមូលនិងប្រធាននាយកដ្ឋាន នឹងត្រូវតែងតាំងដោយអនុក្រឹត្យ ។ អធិការរងមានឋានៈសមមូលនិងអនុប្រធាននាយកដ្ឋាន ដែលនឹងត្រូវតែងតាំង ដោយប្រកាសរបស់ប្រធានស្ថាប័នសាមី ។

មាត្រា១៣ : អគ្គនាយកដ្ឋាន - អគ្គលេខាធិការដ្ឋាន - អគ្គាធិការដ្ឋាន - នាយកដ្ឋាន អធិការដ្ឋាន និងការិយាល័យជាអង្គភាពជានានិរន្តរភាព នៃប្រព័ន្ធរដ្ឋបាលរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៥

## អំពីការត្រួតពិនិត្យហិរញ្ញកិច្ច

មាត្រា១៤ : ក្រសួងឬរដ្ឋលេខាធិការដ្ឋាននិមួយៗ មានអង្គភាពត្រួតពិនិត្យ ហិរញ្ញវត្ថុ ។ អភិបាលត្រួតពិនិត្យហិរញ្ញវត្ថុមួយ ឬ ពីរនាក់ ជ្រើសរើសក្នុងចំណោមមន្ត្រីរាជការមានជំនាញ និង បទពិសោធន៍គ្រប់គ្រាន់ តែងតាំងដោយក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ ត្រូវធ្វើការអមក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។

មាត្រា ១៥ : ការត្រួតពិនិត្យហិរញ្ញកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋទៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ខេត្ត-ក្រុង ។ ក្នុងករណីនេះ អភិបាលត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវរាយការណ៍ភ្លាមនូវបាតុភាពទាំងឡាយ ដែលខ្លួនបានពិនិត្យឃើញជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលខ្លួននៅក្រោមឱវាទ និង ជូនរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការជាប្រធានស្ថាប័នសាមី ។

## ជំពូកទី ៦

## អំពីខុទ្ទកាល័យរបស់ប្រធានស្ថាប័ន

មាត្រា ១៦ : ខុទ្ទកាល័យក្រសួង ឬ រដ្ឋលេខាធិការដ្ឋានជាអង្គភាពដោយឡែក ដែលមានបេសកកម្មជាជំនួយរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្នុងឋានៈរបស់លោកជាអ្នកនយោបាយផ្នែកលើការងារក្នុងរង្វង់រាជរដ្ឋាភិបាល និងរដ្ឋសភាជាតិ ក៏ដូចជាក្នុងឋានៈលោកជាអ្នកដឹកនាំរដ្ឋបាលក្នុងក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន ។

មាត្រា ១៧ : ភារកិច្ចរបស់ខុទ្ទកាល័យមានជាអាទិ៍ :

- រាប់រងទំនាក់ទំនងជាមួយ និង ខុទ្ទកាល័យរបស់រដ្ឋមន្ត្រីឯទៀត ព្រមទាំងទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រ និងប្រព័ន្ធឃោសនាទាំងឡាយ ។
- ផ្តល់យោបល់ជូនរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ចំពោះកិច្ចការទូទៅក្នុងក្រសួង និង ចំពោះសំណុំរឿងទាំងឡាយដែលប្រធានស្ថាប័នបានប្រគល់អោយពិនិត្យ ។ ភារកិច្ចផ្តល់យោបល់នេះមិនផ្តល់សិទ្ធិអោយខុទ្ទកាល័យបំពេញការងារជំនួសអង្គភាពមានសមត្ថកិច្ចនៅក្នុងក្រសួង ឬ រដ្ឋលេខាធិការដ្ឋានឡើយ ។
- ចែកផ្សាយអំពីគោលដៅរបស់ប្រធានស្ថាប័ន ។
- រៀបចំកាលវិភាគរបស់រដ្ឋមន្ត្រី និង អង្គភាពចំណុះក្រសួង រួចតាមដានការអនុវត្តន៍ការងារទាំងនោះអោយស្របតាមកាលវិភាគដែលបានកំណត់ ។
- រៀបចំសម័យប្រជុំការងារក្នុងក្រសួងផ្ទាល់ ព្រមទាំងកិច្ចប្រជុំការងារអន្តរក្រសួង ។
- បញ្ជូនបទបញ្ជារដ្ឋមន្ត្រី ដល់អង្គភាពទាំងឡាយក្នុងក្រសួង តាមកំរិតដែលរដ្ឋមន្ត្រី ប្រធានស្ថាប័នប្រគល់សិទ្ធិអោយ ។
- តាមដាន និង សំរបសំរួលសកម្មភាពផ្សេងៗ ទាំងឡាយរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋានដើម្បីសំរួលការងារ និងតាមដានការអនុវត្តន៍បញ្ជារបស់រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ។

មាត្រា ១៨ : សមាជិកខុទ្ទកាល័យ ត្រូវជ្រើសរើសដោយប្រធានស្ថាប័នផ្ទាល់តាមការស្នើសុំ

និងទំនុកទុកចិត្តរបស់រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការនោះ ហើយអាចបញ្ឈប់សមាជិកណាម្នាក់នៃខុទ្ទកាល័យនោះ បានគ្រប់ពេលវេលាដោយមិនចាំបាច់បញ្ជាក់ពីមូលហេតុអ្វីទាំងអស់ ។ សមាជិកខុទ្ទកាល័យត្រូវចាកចេញពីមុខតំណែងរបស់ខ្លួន ពេលមានការផ្លាស់ប្តូររដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលបានជ្រើសរើសខ្លួន វៀរលែងតែរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ដែលចូលកាន់តំណែងថ្មីបានឯកភាពថារក្សាទុកសមាជិកណាមួយ នៃអតីតខុទ្ទកាល័យ ។

មាត្រា ១៩ : មុខងារ នៃសមាជិកខុទ្ទកាល័យ ជាមុខងារសំរាប់តែមួយរយៈប៉ុណ្ណោះ ។ ហេតុនេះ សមាជិកខុទ្ទកាល័យណា ដែលពីមុនគ្មានលក្ខណសម្បត្តិដើមជាមន្ត្រីក្របខ័ណ្ឌ ពុំអាចទាមទារលក្ខណសម្បត្តិនេះបានដោយយោលទៅលើការតែងតាំងខ្លួនជាសមាជិកខុទ្ទកាល័យនោះឡើយ ផ្ទុយទៅវិញនៅពេលដែលខ្លួនបានចាកចេញពីមុខតំណែងដើម ដើម្បីចូលមកបំរើការខុទ្ទកាល័យ សមាជិកខុទ្ទកាល័យដែលមានលក្ខណសម្បត្តិជាមន្ត្រីក្របខ័ណ្ឌរួចមកហើយត្រូវរក្សាទុកដដែលនូវលក្ខណសម្បត្តិនេះ ព្រមទាំងអតីតភាពរបស់ខ្លួនក្នុងក្រសួង ឬ រដ្ឋលេខាធិការដ្ឋានដើម ។

មាត្រា ២០ : ខុទ្ទកាល័យដឹកនាំដោយនាយកខុទ្ទកាល័យមួយរូប ដែលត្រូវតែងតាំងដោយប្រកាស ។

នាយកខុទ្ទកាល័យមាននាយខុទ្ទកាល័យម្នាក់ ដែលត្រូវតែងតាំងដោយប្រកាសជាអ្នកជំនួយការដែលមានភារកិច្ចជាអាទិ រ៉ាប់រងការងារទាក់ទងពិធីការនិង ទំនាក់ទំនងជាមួយសាធារណជន ។

មាត្រា ២១ : ក្រៅពីនាយកខុទ្ទកាល័យ និងនាយខុទ្ទកាល័យ ខុទ្ទកាល័យអាចមានសមាជិក ÷ ទីប្រឹក្សាបច្ចេកទេស អនុពន្ធសភា អនុពន្ធសារពត៌មាន និងលេខាធិការផ្ទាល់ដែលតែងតាំងដោយប្រកាស ។ មន្ត្រីទាំងនេះមិនត្រូវមានចំនួនលើសពី ៣រូប ចំពោះទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ២រូប ចំពោះរដ្ឋលេខាធិការដែលជាប្រធានស្ថាប័ន និង ១រូប ចំពោះរដ្ឋលេខាធិការដែលពុំមែនជាប្រធានស្ថាប័ន ។ មន្ត្រីខុទ្ទកាល័យខាងលើនេះ ពិនិត្យលើសំណុំរឿងដែលនាយកខុទ្ទកាល័យប្រគល់អោយ ហើយជួយនាយកខុទ្ទកាល័យតាមសមត្ថភាពរបស់ខ្លួនម្នាក់ៗ ។ ការបែងចែកភារកិច្ចរបស់សមាជិកខុទ្ទកាល័យ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋាន ។

មាត្រា ២២ : បន្ថែមលើបុគ្គលិករាជការ ដែលបានកំណត់ក្នុងមាត្រា ២១ ខាងលើ ប្រធានស្ថាប័ននីមួយៗ អាចមានបេសកជន ទីប្រឹក្សា និងជំនួយការដែលបំពេញបេសកកម្ម ក្នុងក្របខ័ណ្ឌខុទ្ទកាល័យ ដែលមានចំនួនសរុបមិនលើសពីបីរូប ហើយត្រូវតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ២៣ : អង្គភាពបុគ្គលិកត្រូវផ្តល់បុគ្គលិកក្របខ័ណ្ឌរបស់ក្រសួង ឬ រដ្ឋលេខាធិការដ្ឋានជូនខុទ្ទកាល័យរ៉ាប់រងលើកិច្ចការផ្នែកផ្គត់ផ្គង់ ដូចជាអ្នកបើកបរ ឬ លេខាធិការ ការិយាល័យ ។ ល ។ មុខតំណែងរបស់ភ្នាក់ងារទាំងអស់នេះ ជាមុខតំណែងរដ្ឋបាលធម្មតាដែលត្រូវមានការផ្លាស់ប្តូរជាស្វ័យប្រវត្តិ នៅពេលដែលមានការផ្លាស់ប្តូររដ្ឋមន្ត្រី ។

## ជំពូកទី ៧

### អវសានបញ្ញត្តិ

**មាត្រា ២៤** : ក្រសួង និង រដ្ឋលេខាធិការដ្ឋានទាំងអស់ត្រូវតែរៀបចំឡើងវិញ នូវរចនាសម្ព័ន្ធអោយស្របតាមបទបញ្ញត្តិ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៥** : បទបញ្ញត្តិផ្ទុយទាំងឡាយណា ដែលមានឋានានុក្រមស្មើ ឬ ទាបជាងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៦** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់មានបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ | ហ៊ុន សែន

បានបង្គំទូលថ្វាយ និង គោរពជូន

នាយករដ្ឋមន្ត្រីទី ១ និងទី ២

សុខ អាន | វេង សិរីវុឌ្ឍ

**កន្លែងទទួល**

- ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋាន នៃរដ្ឋសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ២៣
- ឯកសារ-កាលប្បវត្តិ

<u>ឧបសម្ព័ន្ធ</u>

## គំរូទី ១
## អង្គការលេខ ក្រសួង .........



ឧបសម្ព័ន្ធ

## គំរូទី ២
## អង្គភាពលេខ ក្រសួង .........



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦ អ.ន.ក្រ

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ស្តីពីការតែងតាំង រាជ រដ្ឋាភិបាល កម្ពុជា
- យោង តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ :** ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាស្ថាប័នចំណុះរាជរដ្ឋាភិបាលកម្ពុជា មានសមត្ថកិច្ចគ្រប់គ្រងខេត្ត ក្រុង លើវិស័យរដ្ឋបាល គ្រប់គ្រងនគរបាលជាតិកម្ពុជា និង ការពារ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និង សុវត្ថិភាពជូនប្រជារាស្ត្រ ។

**មាត្រា ២ :** ក្រសួងមហាផ្ទៃមានភារកិច្ច និង សិទ្ធិដូចតទៅ :-

- គ្រប់គ្រងខេត្ត ក្រុង និង មន្ត្រី រាជការ ក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ។
- គ្រប់គ្រងខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ តាមការកំណត់របស់ច្បាប់ ។
- រៀបចំតួនាទី ភារកិច្ច សិទ្ធិ និង អង្គការលេខរបស់ខេត្ត ក្រុង ។
- តាមដានត្រួតពិនិត្យសកម្មភាពការងារ របស់ថ្នាក់ ខេត្ត ក្រុង ។
- ទទួលពាក្យបណ្តឹងតវ៉ា របស់ប្រជារាស្ត្រ និង ដោះស្រាយតាមសមត្ថកិច្ច ដែលច្បាប់ប្រគល់អោយ ហើយដែលមានការពាក់ព័ន្ធដល់ការងាររបស់ថ្នាក់ខេត្ត ក្រុង ។
- ដឹកនាំអនុវត្តការងារគ្រប់គ្រងផែនការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ខេត្ត ក្រុង និង ជំរុញការងាររៀបចំកែទម្រង់ ជីវភាពរស់នៅខាងស្មារតី សំភារៈ និង វប្បធម៌ជូនប្រជារាស្ត្រ ។ ៗ/ល្ង

- បង្ការ និង បង្ក្រាបបទល្មើសព្រហ្មទណ្ឌ ភេរវកម្ម បទល្មើសសេដ្ឋកិច្ច ការរត់ពន្ធគ្រឿងញៀន និង បទល្មើសផ្សេង ៗ ប្រឆាំងនឹងសន្តិសុខ ផ្ទៃក្នុងប្រទេស ។

- បង្ការ និង បង្ក្រាប អំពើពាលអនាថា និង អំពើល្មើសផ្សេង ៗ ទៀត ។

- ស៊ើបអង្កេតស្រាវជ្រាវបទល្មើសគ្រប់ប្រភេទចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួន បណ្ដោះអាសន្ន កសាង សំណុំរឿង និង បញ្ជូនសំណុំរឿងជនល្មើស ព្រមទាំងភស្តុតាង ទៅអយ្យការគ្រប់ថ្នាក់ ។

- អនុវត្ត និង សហការអនុវត្ត សាលក្រម ផ្ទន្ទាទោសដាក់ពន្ធនាគារ ដីកា និង សេចក្ដីសំរេចរបស់ តុលាការ និង អយ្យការគ្រប់ថ្នាក់ ។

- គ្រប់គ្រងប៉ុស្ដិ៍នគរបាលរដ្ឋបាល ។

- គ្រប់គ្រងប៉ុស្ដិ៍នគរបាលព្រំដែនគោក ទឹក និង ព្រំដែនសមុទ្រ ។

- គ្រប់គ្រងសន្តិសុខ សណ្ដាប់ធ្នាប់នៅច្រកទ្វារព្រំដែន គោក ទឹក សមុទ្រ និង អាកាស ។

- ហ្វឹកហ្វឺន បណ្ដុះបណ្ដាល និង វិក្រឹតការមុខជំនាញ អោយដល់មន្ត្រីរាជការរដ្ឋបាល និង នគរបាល ជាតិគ្រប់ថ្នាក់ ។

- គ្រប់គ្រងចលនវត្ថុ និង អចលនវត្ថុរបស់ក្រសួង ។

- គ្រប់គ្រងហិរញ្ញវត្ថុ ភស្តុភារ មធ្យោបាយ សម្ភារៈឧបករណ៍ បច្ចេកទេស និងសំណង់របស់ ក្រសួង ។

- ស្រាវជ្រាវរកមនុស្សបាត់ខ្លួន ។

- សំណូមពរអោយក្រសួង ស្ថាប័ន អង្គការសង្គម និងប្រជារាស្ត្រចូលរួមសហការក្នុងការបំពេញ ភារកិច្ចចាំបាច់របស់ខ្លួន ។

- បង្គាប់អភិបាលខេត្ត ក្រុងអោយរាយការណ៍តាមការកំណត់ និងសំណូមពរអោយក្រសួង និង ស្ថាប័ននានាផ្ដល់ជាបន្ទាន់នូវព័ត៌មាន និងឯកសារដែលមានការពាក់ព័ន្ធដល់សន្តិសុខជាតិ ។ ក្នុងករណី ពិសេសអាចស្នើសុំតំណាង ស្ថាប័នរដ្ឋ ដែលមានការពាក់ព័ន្ធអោយចូលរួមសហការបំពេញភារកិច្ចជា មួយនគរបាលជាតិកម្ពុជា ។

- ផ្អាកជាបណ្ដោះអាសន្ន ដីកា ខេត្ត ក្រុង ក្នុងករណីមានការប្ដឹងជំទាស់ ដើម្បីធ្វើការត្រួតពិនិត្យ ឡើងវិញ ។ (ម្ង៉ែ

- ចេញបញ្ជា និង ចាត់វិធានការជាបន្ទាន់ដើម្បីបង្ការ និងបង្ក្រាបនូវរាល់សកម្មភាពដែលបង្កនូវគ្រោះមហន្តរាយ ដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងជីវភាពរស់នៅរបស់ ប្រជារាស្ត្រ ។

- អនុវត្តភារកិច្ច និងសិទ្ធិផ្សេង ៗ ទៀត ដែលរាជរដ្ឋាភិបាលកម្ពុជាប្រគល់អោយ ។

មាត្រា ៣ : នគរបាលជាតិកម្ពុជា ដែលចុះទៅបំពេញ បេសកកម្មមានអាទិភាពក្នុងការធ្វើដំណើរ ទៅមកតាមមធ្យោបាយគមនាគមន៍ សាធារណៈ ។ ក្នុងករណីពិសេសបន្ទាន់ ( បង្ក្រាប បទឧក្រិដ្ឋកម្ម ឬ ជួយបង្គ្រោះបន្ទាន់ ) នគរបាលជាតិ មានសិទ្ធិប្រើប្រាស់មធ្យោបាយ ទូរគមនាគមន៍ និង មធ្យោបាយ បច្ចេកទេសផ្សេង ៗ ទៀត របស់អង្គការរដ្ឋ អង្គការសង្គម ។ ក្នុងករណីនេះ ឯកជនត្រូវចូលរួមសហការជាមួយនគបាលជាតិមានសមត្ថកិច្ច ។

មាត្រា ៤ : ក្រសួងមហាផ្ទៃ ដឹកនាំដោយរដ្ឋមន្ត្រី រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ ។

មាត្រា ៥ : ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានរចនាសម្ព័ន្ធដូចតទៅ :

- ខុទ្ទកាល័យ
- អគ្គាធិការដ្ឋាន កិច្ចការនយោបាយ រដ្ឋបាល និង នគរបាល
- អគ្គ នាយកដ្ឋានរដ្ឋបាល
- អគ្គ នាយកដ្ឋាន នគរបាលជាតិ –> អគ្គស្នងការនគរបាលជាតិ

ក – អគ្គនាយកដ្ឋានរដ្ឋបាល មាន ៤ នាយកដ្ឋាន :

១ – នាយកដ្ឋាន រដ្ឋបាលទូទៅ

២ – នាយកដ្ឋាន កិច្ចការ នយោបាយ

៣ – នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាលវិជ្ជាជីវៈ

៤ – នាយកដ្ឋាន ពន្ធនាគារ

ខ – អគ្គនាយកដ្ឋាននគរបាលជាតិមាន :

- សេនាធិការដ្ឋាន
- ការិយាល័យនគរបាលអន្តរជាតិ
- អង្គភាពអន្តរាគមន៍
- នាយកដ្ឋានកណ្តាល ប្រាំ ១-២៣

I – នាយកដ្ឋានកណ្តាល នគរបាលព្រំដែនមាន បី នាយកដ្ឋាន

១ – នាយកដ្ឋាននគរបាលព្រំដែនគោក

២ – នាយកដ្ឋាននគរបាលព្រំដែនទឹក

៣ – នាយកដ្ឋានបច្ចេកទេសព្រំដែន

II – នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់ សាធារណៈមានបួននាយកដ្ឋាន

១ – នាយកដ្ឋាន សន្តិសុខសង្គម

២ – នាយកដ្ឋាននគរបាលការពារ

៣ – នាយកដ្ឋាននគរបាលរដ្ឋបាល

៤ – នាយកដ្ឋានសណ្តាប់ធ្នាប់

III – នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ មាន បី នាយកដ្ឋាន

១ – នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

២ – នាយកដ្ឋាននគរបាលសេដ្ឋកិច្ច

៣ – នាយកដ្ឋាននគរបាលបច្ចេកទេស និង វិទ្យាសាស្ត្រ

IV – នាយកដ្ឋានកណ្តាលសន្តិសុខមាន បួន នាយកដ្ឋាន

១ – នាយកដ្ឋានពត៌មានទូទៅ

២ – នាយកដ្ឋានប្រឆាំងភេរវកម្ម

៣ – នាយកដ្ឋានជនបរទេស

៤ – នាយកដ្ឋានអង្គរក្ស

V – នាយកដ្ឋានកណ្តាលមធ្យោបាយ មាន បី នាយកដ្ឋាន

១ – នាយកដ្ឋានបុគ្គលិក

២ – នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ

៣ – នាយកដ្ឋានភស្តុភារ និង សំភារៈបច្ចេកទេស

គ – ក្រោមឱវាទរួមរបស់អគ្គនាយកដ្ឋានរដ្ឋបាល និង អគ្គនាយកដ្ឋាននគរបាលជាតិមាន ប្រាំពីរ

នាយកដ្ឋាន (៧)ៈ

១ - នាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២ - នាយកដ្ឋានវិទ្យុទាក់ទង

៣ - នាយកដ្ឋានបំភ័ន្តអក្ខរៈ

៤ - នាយកដ្ឋានផ្សព្វផ្សាយអប់រំ

៥ - នាយកដ្ឋាន នីតិកម្ម

៦ - នាយកដ្ឋាន សុខាភិបាល

៧ - នាយកដ្ឋានស្ថាបនា

ខុទ្ទកាល័យ អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋានកណ្តាល នាយកដ្ឋាន សេនាធិការដ្ឋាន ការិយាល័យនគរបាលអន្តរជាតិ និង អង្គភាពអន្តរាគមន៍ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជំនួយការ ។

ប្រធាននាយកដ្ឋានកណ្តាល ថ្នាក់ស្មើអគ្គនាយករង ។

អនុប្រធាននាយកដ្ឋានកណ្តាលថ្នាក់ស្មើប្រធាននាយកដ្ឋាន ។

សេនាធិការដ្ឋាន ការិយាល័យ នគរបាលអន្តរជាតិ អង្គភាពអន្តរាគមន៍ ថ្នាក់ស្មើនាយកដ្ឋាន ។

មាត្រា ៦ : រចនាសម្ពន្ធចាត់តាំងរដ្ឋបាល នៅមូលដ្ឋានរួមមាន

- សាលាខេត្ត ក្រុង
- សាលាស្រុក ខ័ណ្ឌ
- សាលាឃុំ សង្កាត់

សាលាខេត្ត ក្រុង សាលាស្រុក ខ័ណ្ឌ និង សាលាឃុំ សង្កាត់ ដឹកនាំដោយអភិបាលខេត្ត ក្រុង អភិបាលស្រុក ខ័ណ្ឌ មេឃុំ ចៅសង្កាត់ មួយរូប និង អភិបាលរង ខេត្ត ក្រុង អភិបាលរង ស្រុក ខ័ណ្ឌ ជំទប់ ជាជំនួយការ ។

មាត្រា ៧ : រចនាសម្ព័ន្ធចាត់តាំង នគរបាលជាតិកម្ពុជា នៅមូលដ្ឋានរួមមាន :

- ស្នងការដ្ឋាននគរបាលខេត្ត ក្រុង
- អធិការដ្ឋាន នគរបាលស្រុក ខ័ណ្ឌ
- ប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំ...

– សហការជាមួយក្រសួងពាក់ព័ន្ធក្នុងការរៀបចំទីតាំង ភូមិឋានរបស់ប្រជារាស្ត្រអោយស្របទៅតាមលក្ខណៈភូមិសាស្ត្រ ទំនៀមទំលាប់ ប្រពៃណី សាសនារបស់ប្រជារាស្ត្រ ។

– គ្រប់គ្រងពន្ធនាគារ ។

– ការពារអាយុជីវិត សិទ្ធិសេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងផលប្រយោជន៍ ស្របច្បាប់របស់ប្រជារាស្ត្រ ។

– ការពារសុវត្ថិភាព ថ្នាក់ដឹកនាំជាតិ និង អន្តរជាតិ ។

– ការពារការសំងាត់ជាតិ ។

– ការពារស្ថាប័នជាតិ ។

– ការពារទ្រព្យសម្បត្តិសាធារណៈ ។

– ការពារស្ថាប័នទូត អង្គការអន្តរជាតិនានា គណៈរបតិភូអន្តរជាតិ និង ជនបរទេសដែលស្នាក់នៅព្រះរាជាណាចក្រកម្ពុជា។

– ការពារសម្បត្តិវប្បធម៌ និង បេតិកភ័ណ្ឌជាតិ ។

– ការពារសន្តិសុខ សណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន ។

– គ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជារាស្ត្រ ជនបរទេស មុខរបរ ការផ្តល់អត្តសញ្ញាណប័ណ្ណពលរដ្ឋ ប័ណ្ណសំគាល់ខ្លួន ជនអន្តោប្រវេសន្ត និង ការផ្តល់លិខិតឆ្លងដែនពលរដ្ឋ ។

– ធ្វើបញ្ជី ពលរដ្ឋ មានសិទ្ធិបោះឆ្នោត និង រៀបចំការបោះឆ្នោតផ្សេងៗ តាមច្បាប់ ។

– ប្ញូតសរុបលើគ្រប់វិស័យការងាររបស់ខេត្ត ក្រុង ។

– គ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ និង ចរាចរផ្លូវគោក ផ្លូវទឹក ។

– គ្រប់គ្រងការងារ បង្ការ និង ពន្លត់អគ្គីភ័យ ។

– គ្រប់គ្រងមន្ទីរពេទ្យ គិលានដ្ឋានរបស់ក្រសួង, ។

– គ្រប់គ្រងការប្រើប្រាស់ វិទ្យុទាក់ទងផ្នែកនគរបាល និង ស៊ីវិល ។

– គ្រប់គ្រងការងារបំភ័ន្តអក្សរ ។

– គ្រប់គ្រង និង ត្រួតពិនិត្យការប្រើប្រាស់ ការដឹកនាំអាវុធ គ្រឿងផ្ទុះ ជាតិពុល និង ផ្តល់លិខិតអនុញ្ញាតប្រើប្រាស់អាវុធផ្នែកស៊ីវិល ។ ៤/៦៩

ស្នងការដ្ឋាន អធិការដ្ឋាន ប៉ុស្តិ៍នគរបាលរដ្ឋបាល ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជំនួយការ ។

មាត្រា ៨ : ការរៀបចំតួនាទីភារកិច្ច សិទ្ធិ និង រចនាសម្ព័ន្ធ របស់ខេត្ត ក្រុង ត្រូវកំណត់ដោយប្រកាសក្រសួង ។

មាត្រា ៩ : ការរៀបចំតួនាទីភារកិច្ច សិទ្ធិ និង រចនាសម្ព័ន្ធរបស់ខុទ្ទកាល័យ អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋានកណ្តាល នាយកដ្ឋាន សេនាធិការដ្ឋាន ការិយាល័យ នគរបាលអន្តរជាតិ អង្គភាពអន្តរាគមន៍ និង ស្នងការដ្ឋាន ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

មាត្រា ១០ : ក្រសួងមហាផ្ទៃ អាចចេញប្រកាសរួមក្នុងនាមអន្តរក្រសួងលើករណីដែល មានការទាក់ទងដល់តួនាទីភារកិច្ច សិទ្ធិអំណាចរបស់ខ្លួនជាមួយក្រសួង ស្ថាប័នផ្សេង ១ ទៀត ។

មាត្រា ១១ : ក្របខ័ណ្ឌមន្ត្រីរាជការ រដ្ឋបាលនគរបាលជាតិ និង ទីប្រឹក្សារបស់ក្រសួងមហាផ្ទៃត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។

មាត្រា ១២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុរដ្ឋលេខាធិការមុខងារសាធារណៈ រដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ និង អភិបាលគ្រប់ ខេត្ត ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។ ៚

ភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣

ជ.រាជរដ្ឋាភិបាល

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា | ហត្ថលេខា |
| សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

---

លេខ : ០០I---- ច.ល.

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ឌឹម ឈុន្នូលីម ១៨


ក្រសួងបរិស្ថាន
ខុទ្ទកាល័យ
នាយកដ្ឋានរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា

ជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០៨ អនុក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមអ្នកច្បាប់ និង នាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ និង អាស៊ាន ចំណុះក្រសួងមហាផ្ទៃ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

## ជំពូកទី ១

## អំពីក្រុមអ្នកច្បាប់

មាត្រា ១ : បង្កើតក្រុមអ្នកច្បាប់របស់ក្រសួងមហាផ្ទៃ ចំណុះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖